ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**សូមគោរពជូន**

**លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ**

**និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**

**តាមរយៈ** លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ

**កម្មវត្ថុ៖** វគ្គបណ្តុះបណ្តាល ស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងផ្តល់សេវាសមស្រប ។

ថ្ងៃពុធ-សុក្រ ៧-៩ កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៣-២៥ ខែសីហា ឆ្នាំ២០២៣ មានបើកវគ្គបណ្តុះបណ្តាល ស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងផ្តល់សេវាសមស្រប ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ វគ្គបណ្តុះបណ្តាលនេះចូលរួមសហការ និងសម្របសម្រួលដោយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ(IOM) ។

I.**សមាសភាពចូលរួម៖**

១.លោកស្រី គ្រីស្ទីន ផាកូ ប្រធានបេសកកម្មអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM)
២.លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ
៣.លោកស្រី កែវ ម៉ាលី ទីប្រឹក្សាក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា(គ្រូឧទ្ទេស)
៤.ឯកឧត្តម ឧត្តមសេនីយ៍ឯក យ៉ែម ច័ន្ទណារុំ អគ្គលេខាធិការរង គ.ជ.ប.ជ
៥.ឯកឧត្តម ឧត្តមសេនីយ៍ឯក លី តុងហ៊ុយ អគ្គលេខាធិការរង គ.ជ.ប.ជ(គ្រូឧទ្ទេស)
៦.លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង គ.ជ.ប.ជ(គ្រូឧទ្ទេស)
៧.លោក ឧត្តមសេនីយ៍ទោ សេក ស៊ីវ៉េត ប្រធានក្រុមជំនួយកិច្ចការការពារជនរងគ្រោះនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ (គ្រូឧទ្ទេស)
៨.លោក ឧត្តមសេនីយ៍ទោ រ៉ែន សុភ័ក្រវឌ្ឍនា ប្រធានក្រុមជំនួយកិច្ចការបង្ការទប់ស្កាត់នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ(គ្រូឧទ្ទេស)
៩.លោក ឧត្តមសេនីយ៍ត្រី អ៊ិន មាន ប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ អន្តរជាតិ (គ្រូឧទ្ទេស)
១០.លោក ឯក សំអុល តំណាងអង្គការ IOM
១១.លោកស្រី វរសេនីយ៍ឯក ថោង សុវត្ថិ អនុប្រធានក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិ និងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ (គ្រូឧទ្ទេស)
១២.លោក វរសេនីយ៍ទោ ហង្ស ពុទ្ធារិទ្ធិ នាយការិយាល័យ (គ្រូឧទ្ទេស)
១៣.ក្រុមការងារបច្ចេកទេស នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ និង អង្គការ IOM
១៤.សិក្ខាកាមមកពីខេត្តព្រៃវែង ចំនួន ៤១ រូប ស្រី ២១ រូប

១៥.កំពង់ធំ ចំនួន ២៩ រូប ស្រី ១៨ រូប

សរុបចំនួន ៨៩ រូប ស្រី ៤៧ រូប ។

## II.ប្រសាសន៍ស្វាគមន៍ និងបើកវគ្គបណ្តុះបណ្តាល

១. **លោកស្រី ត្រឺស្ទីន ផារ៉ូ** ប្រធានបេសកកម្មអង្គការ IOM ប្រចាំកម្ពុជា បានមានមតិចូលរួមក្នុងការបើកវគ្គបណ្តុះបណ្តាលដល់សិក្ខាកាមដែលមកពីខេត្តកំពង់ធំ និងព្រៃវែង គឺជាបុព្វហេតុ នៃការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសូមថ្លែងអំណរគុណ កោតសរសើរចំពោះ **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍** គ.ជ.ប.ជ ដែលបានដឹកនាំការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅកម្ពុជា ។ **លោកស្រី** បានបញ្ជាក់ថា ក្នុងភាពជាដៃគូសហការ IOM នៅតែបន្តចូលរួមគាំទ្រជាមួយរាជរដ្ឋាភិបាល ក៏ដូចជាគណៈកម្មាធិការជាតិ ក្នុងការអនុវត្តច្បាប់ និងផ្តល់សេវាសមស្របដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

២. **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍** គ.ជ.ប.ជ មានប្រសាសន៍នៅក្នុងការបើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណដោយអំពើជួញដូរមនុស្ស និងផ្តល់សេវាសមស្រប ដោយ **លោកជំទាវ** បានបញ្ជាក់ថា ការបើកវគ្គបណ្តុះបណ្តាលនាពេលនេះ គឺមានសារៈសំខាន់ខ្លាំងណាស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីអ្នកអនុវត្តការងារថ្នាក់ក្រោមជាតិឲ្យទទួលបាននូវចំណេះដឹង ក្នុងការសង្កេត សាកសួរប្រមូលព័ត៌មានពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាចសន្និដ្ឋានបណ្តោះអាសន្នថាជា ជនរងគ្រោះ ឬជា ជនសង្ស័យ ដើម្បីផ្តល់សេវាសមស្របប្រកបដោយមនុស្សធម៌ មិនរើសអើង ឬមានវិធានការបន្តប្រសិនបើគាត់មិនមែនជាជនរងគ្រោះ ។ **លោកជំទាវ** មានប្រសាសន៍បញ្ជាក់ថា មន្ត្រីពាក់ព័ន្ធលើការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ត្រូវធ្វើសកម្មភាពជាក់ស្តែងតាមរចនាសម្ព័ន្ធ កុំឲ្យមានតែរចនាសម្ព័ន្ធលើក្រដាសពីព្រោះយើងមានរចនាសម្ព័ន្ធត្រឹមត្រូវច្បាស់លាស់ ប៉ុន្តែហាក់នៅមានចំណុចចន្លោះប្រហោងដែលឧក្រិដ្ឋជនអាចធ្វើសកម្មភាពបាន ។ យើងត្រូវខិតខំប្រឹងប្រែងអនុវត្តការងារបន្តទៀត ដើម្បីរួមគ្នាទប់ស្កាត់គ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ដែលពិភពលោកកំពុងតែធ្វើសកម្មភាពទប់ស្កាត់យ៉ាងខ្លាំង ។ **លោកជំទាវ** មានប្រសាសន៍បន្តថា រាជរដ្ឋាភិបាលកម្ពុជា បាន និងកំពុងបានធ្វើសកម្មភាពឥតឈប់ឈរដើម្បីការពារជនរងគ្រោះ ជួយប្រជាជនខ្លួន រួមទាំងជនបរទេសដែលរស់នៅក្នុងទឹកដីកម្ពុជា ពីអំពើជួញដូរមនុស្ស និងការបង្ខាំងមនុស្សខុសច្បាប់ ។ **លោកជំទាវ** មានប្រសាសន៍ថ្លែងអំណរគុណចំពោះអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) ដែលតែងតែចូលរួមគាំទ្រ សហការយ៉ាងល្អប្រសើរជាមួយ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់សកម្មភាពពាក់ព័ន្ធការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ **លោកជំទាវ** មានប្រសាសន៍បន្តថា តាងនាមថ្នាក់ដឹកនាំគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សូមថ្លែងអំណរគុណ និងរីករាយបំផុតក្នុងកិច្ចសហការរបស់អង្គការ IOM និងសូមស្វាគមន៍ជានិច្ចក្នុងការចូលរួមគាំទ្រ សហការជាមួយគ្នានៅលើកក្រោយទៀត ។

## III.ដំណើរការវគ្គបណ្តុះបណ្តាល

វគ្គបណ្តុះបណ្តាល ស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងផ្តល់សេវាសមស្រប បានដំណើរការរយៈពេល ៣ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៣ មានសិក្ខាកាមអញ្ជើញមកពីខេត្តព្រៃវែង **ចំនួន ៤១ រូប ស្រី ២១ រូប និងកំពង់ធំ ចំនួន ២៩ រូប ស្រី ១៨ រូប សរុបចំនួន ៧០ រូប ស្រី ៣៩ រូប ។**

***ថ្ងៃទី១៖ ទី២៣ ខែសីហា ឆ្នាំ២០២៣***

វគ្គបណ្តុះបណ្តាល ស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងផ្តល់សេវាសមស្រប ត្រូវបានបែងចែកជាពីរក្រុម៖

- ❖ ក្រុមទី១៖ សិក្ខាកាមមកពីខេត្តព្រៃវែង (គ្រូឧទ្ទេសៈ លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ន សិរីក្ខិណា, លោក ឧត្តមសេនីយ៍ទោ រ៉ន សុភ័ក្ត្រវឌ្ឍនា, លោក ឧត្តមសេនីយ៍ត្រី អ៊ិន មាន, លោកស្រី វរសេនីយ៍ឯក ថោង សុវត្ថិ, លោក ឯក សំអុល) ។
- ❖ ក្រុមទី២៖ សិក្ខាកាមមកពីខេត្តកំពង់ធំ (គ្រូឧទ្ទេសៈ លោកស្រី កែវ ម៉ាលី, ឯកឧត្តម ឧត្តមសេនីយ៍ឯក លី តុងហ៊ុយ, លោក ឧត្តមសេនីយ៍ទោ សេក ស៊ីវ៉េត, លោក វរសេនីយ៍ទោ ហង្ស ពុទ្ធារិទ្ធិ, លោក ឯក សំអុល) ។ ក្រុមទាំង ០២ ត្រូវបានសិក្សាមេរៀនចំនួន ០៨ ដូចខាងក្រោម៖
  - ✓ មេរៀនទី១៖ សារៈសំខាន់ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណ (សំណួរ/ចម្លើយ) ល.ជ ឧ.ទោ រ៉ន សិរីលក្ខិណា / ឧ.ទោ សេក ស៊ីវ៉េត
  - ✓ មេរៀនទី២៖ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសម្រាប់ការអនុវត្ត (សំណួរ/ចម្លើយ) ឧ.ទោ រ៉ន សុភ័ក្ត្រវឌ្ឍនា / ឧ.ឯក លី តុងហ៊ុយ
  - ✓ មេរៀនទី៣៖ វិធានការចាំបាច់ត្រូវយល់ដឹងមុនកិច្ចសម្ភាសន៍ (សំណួរ/ចម្លើយ) ឧ.ត្រី អ៊ិន មាន / វ.ទោ ហង្ស ពុទ្ធារិទ្ធិ

**ថ្ងៃទី២៖ ទី២៤ ខែសីហា ឆ្នាំ២០២៣**

- ✓ មេរៀនទី៤៖ ការសម្ភាសន៍រហ័សដោយប្រើទម្រង់ខ្លី (សំណួរ/ចម្លើយ) ឧ.ត្រី អ៊ិន មាន / ឧ.ឯក លី តុងហ៊ុយ
- ✓ មេរៀនទី៥៖ ទម្រង់វែង សម្រាប់ការសម្ភាសន៍លម្អិត (សំណួរ/ចម្លើយ) ល.ជ ឧ.ទោ រ៉ន សិរីលក្ខិណា / ឧ.ទោ សេក ស៊ីវ៉េត
- ✓ មេរៀនទី៦៖ ការផ្តល់សេវា និងសិទ្ធិជនរងគ្រោះ (សំណួរ/ចម្លើយ) លោក ឯក សំអុល / លោកស្រី កែវ ម៉ាលី
- ✓ មេរៀនទី៧៖ តួនាទី និងភារកិច្ចរបស់អង្គភាព ស្ថាប័ន ក្នុងការជួយជនរងគ្រោះ (សំណួរ/ចម្លើយ) ឧ.ត្រី អ៊ិន មាន / ឧ.ទោ សេក ស៊ីវ៉េត
- ✓ មេរៀនទី៨៖ បែបបទ និងនីតិវិធី នៃការបញ្ជូន (សំណួរ/ចម្លើយ) ឧ.ទោ រ៉ន សុភ័ក្ត្រវឌ្ឍនា / លោកស្រី កែវ ម៉ាលី

**ក.ការធ្វើតេស្ត**

- ➢ ការធ្វើតេស្តមុនវគ្គ ដើម្បីដឹងអំពីចំណេះដឹង និងបទពិសោធន៍របស់សិក្ខាកាម
- ➢ ធ្វើតេស្តសាកល្បងជាក្រុម ដោយអនុវត្តបំពេញលើទម្រង់សម្ភាសន៍បឋម(ខ្លី) និងទម្រង់សម្ភាសន៍លម្អិត (វែង) ដែលបានបែងចែកចំនួន ០៦ ក្រុម ។

**ខ.ការពិភាក្សាក្រុម**

- ➢ បែងចែកក្រុមពិភាក្សាជាក្រុម ដែលបានបែងចែកចំនួន ០៤ ក្រុម ដោយក្រុមនីមួយៗត្រូវសហការឆ្លើយនូវសំណួរដូចខាងក្រោម៖

១. ការអនុវត្តបច្ចុប្បន្ន

- តើអ្នកណាជាអ្នកពាក់ព័ន្ធសំខាន់ៗ ដែលចូលរួមក្នុងដំណើរការបញ្ជូន?
- តើប្រព័ន្ធបញ្ជូនមានប្រសិទ្ធិភាពយ៉ាងណាក្នុងការធានាសុវត្ថិភាព និងការពារជនរងគ្រោះ?

២. ការសហការ និងការសម្របសម្រួល

- តើភ្នាក់ងារ និងអង្គការផ្សេងៗអាចសហការគ្នាឲ្យកាន់តែមានប្រសិទ្ធភាព ដើម្បីធានាបាននូវដំណើរការបញ្ជូនបន្តដោយរលូនដោយរបៀបណា?

- តើមានបញ្ហាប្រឈមអ្វីខ្លះក្នុងការប្រាស្រ័យទាក់ទង រវាងភាគីពាក់ព័ន្ធផ្សេងៗ ដែលចាំបាច់ត្រូវដោះស្រាយ?

៣. ការចែករំលែកទិន្នន័យ និងភាពឯកជន

- តើបច្ចេកវិទ្យា ឬវិធីសាស្ត្រណាខ្លះ ដែលអាចប្រើបានដើម្បីចែករំលែក ផ្តល់ព័ត៌មានពាក់ព័ន្ធដោយសុវត្ថិភាព?

**គ.ការបកស្រាយរបស់ក្រុមពិភាក្សាទាំង៤៖**

សិក្ខាកាមទាំង ៤ក្រុម ខាងលើបានសហការធ្វើការឆ្លើយតប និងបកស្រាយអំពីលទ្ធផលដែលបានពិភាក្សាគ្នាចំពោះសំណួរសាកល្បង ទាំង០៣ ចំណុច យ៉ាងក្បោះក្បាយដោយភាពសប្បាយរីករាយ ។

***ថ្ងៃទី៣៖ ទី២៥ ខែសីហា ឆ្នាំ២០២៣***

**ការរំលឹកមេរៀន**

វគ្គបណ្តុះបណ្តាល ស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងផ្តល់សេវាសមស្រប បានធ្វើការបែងចែកសិក្ខាកាមចំនួន ២ក្រុម ដោយក្រុមនីមួយៗត្រូវធ្វើការជ្រើសរើសសំនួរដើម្បីឆ្លើយតប និងពន្យល់បកស្រាយប្រកួតប្រជែងគ្នា ដែលបានរៀបចំដោយក្រុមគ្រូឧទ្ទេស ។ ក្រុមនីមួយៗ បានខិតខំចូលរួមសហការឆ្លើយតប ពន្យល់យ៉ាងផុលផុស (លោក ឯក សំអុល IOM)។

**IV.មេរៀនជំនួយស្មារតី៖**

- យល់ដឹងអំពីសញ្ញាណ នៃការប៉ះទង្គិចផ្លូវចិត្ត ដោយអំពើជួញដូរមនុស្ស (សំណួរ/ចម្លើយ) លោកស្រី វ.ឯក វេជ្ជបណ្ឌិត ថោង សុវត្ថិ / ឧ.ទោ សេក ស៊ីវ៉េត)
- ក្រមសីលធម៌របស់អ្នកសម្ភាសន៍(សំណួរ/ចម្លើយ) ល.ជ ឧ.ទោ រ៉ន សិរីលក្ខិណា/ វ.ទោ ហង្ស ពុទ្ធារិទ្ធិ)
- ការទស្សនាវីដេអូ បទយកការណ៍ ស្តីពីការពពោះជំនួស និងវីដេអូខ្លី (ភាគចិន) ការអូសទាញ និងកល់ល្បិចរបស់ជនល្មើស (ល.ជ ឧ.ទោ រ៉ន សិរីលក្ខិណា / ឧ.ទោ រ៉ន សុភ័ក្ត្រវឌ្ឍនា)

➢ **ការធ្វើតេស្ត និងការវាយតម្លៃរបស់សិក្ខាកាមក្រោយវគ្គ**

បន្ទាប់ពីបានសិក្សាមេរៀន ស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងផ្តល់សេវាសមស្រប រយៈពេល ៣ថ្ងៃកន្លងមក សិក្ខាកាមទាំងអស់ត្រូវបានធ្វើតេស្តក្រោយវគ្គបណ្តុះបណ្តាលតាមរយៈប្រព័ន្ធ Telegram និងបានធ្វើការបំពេញទម្រង់វាយតម្លៃវគ្គបណ្តុះបណ្តាលនេះផងដែរ ។

**V.ពិធីសំណេះសំណាលបិទវគ្គបណ្តុះបណ្តាល និងវាយតម្លៃ**

**លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានធ្វើសេចក្តីរាយការណ៍ជូនគណៈអធិបតី និងសិក្ខាកាមទាំងអស់ អំពីវិធីសាស្ត្រ និងលទ្ធផលវគ្គបណ្តុះបណ្តាល ស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងផ្តល់សេវាសមស្រប ដែលបានប្រព្រឹត្តទៅរយៈពេល ៣ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី២៣ ដល់ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២៣ ដូចតទៅ៖

១.គោលបំណង នៃការបើកវគ្គបណ្តុះបណ្តាល

ដើម្បីឲ្យសិក្ខាកាមបានយល់ដឹងអំពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប និងស៊ើបអង្កេត ស្រាវជ្រាវជនប្រព្រឹត្តបទល្មើស រួមទាំងបក្សពួកមកទទួលទោសតាមច្បាប់ និងឲ្យដឹងច្បាស់អំពីច្បាប់ជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ព្រមទាំងច្បាប់ពាក់ព័ន្ធមួយចំនួនទៀត ។

២.សមាសភាពគ្រូបង្គោល និងអ្នកសម្របសម្រួល៖

អញ្ជើញមកពី អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិ គ.ជ.ប.ជ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អង្គការទេសន្តរប្រវេសន៍អន្តរជាតិ(IOM) ។

៣.អំពីសមាសភាព៖

- សមាសភាពគ្រូឧទ្ទេស

  -មកពីគណៈលេខាធិការដ្ឋាន គ.ជ.ប.ជ

  -មកពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

  -មកពីអង្គការទេសន្តរប្រវេសន៍អន្តរជាតិ IOM

- សមាសភាពសិក្ខាកាម

  អញ្ជើញមកពីខេត្តចំនួន ០២ ដែលមានសមាសភាពមកពីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អភិបាល អភិបាលរង អធិការ អធិការរង ក.គ.ស.ក ក្រុង/ស្រុក រួមមាន ៖ ខេត្តព្រៃវែង ចំនួន ៤១ រូប ស្រី ២១ រូប និង ខេត្តកំពង់ធំ ចំនួន ២៩ រូប ស្រី ១៨ រូប សរុបចំនួន ៧០ រូប ស្រី ៣៩ រូប ។

៤.ខ្លឹមសារមេរៀន និងវិធីសាស្ត្របណ្តុះបណ្តាល៖

- **ខ្លឹមសារមេរៀន**

  -មេរៀនទី១៖ សារៈសំខាន់ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណ

  -មេរៀនទី២៖ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធសម្រាប់ការអនុវត្ត

  -មេរៀនទី៣៖ វិធានការចាំបាច់ត្រូវយល់ដឹងមុនកិច្ចសម្ភាសន៍

  -មេរៀនទី៤៖ ការសម្ភាសន៍រហ័សដោយប្រើទម្រង់ខ្លី

  -មេរៀនទី៥៖ ទម្រង់វែង សម្រាប់ការសម្ភាសន៍លម្អិត

  -មេរៀនទិ៦៖ ការផ្តល់សេវា និងសិទ្ធិជនរងគ្រោះ

  -មេរៀនទី៧៖ តួនាទី និងភារកិច្ចរបស់អង្គភាព ស្ថាប័ន ក្នុងការជួយជនរងគ្រោះ

  -មេរៀនទី៨៖ បែបបទ និងនីតិវិធី នៃការបញ្ជូន

- **មេរៀនជំនួយស្មារតី**

  -យល់ដឹងអំពីសញ្ញាណ នៃការប៉ះទង្គិចផ្លូវចិត្ត ដោយអំពើជួញដូរមនុស្ស

  -ក្រមសីលធម៌ របស់អ្នកសម្ភាសន៍

- **វិធីសាស្ត្របណ្តុះបណ្តាល**

  -ចែកសៀវភៅគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធី នៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប

  -ចែកសៀវភៅច្បាប់ ស្តីពីច្បាប់ប្រឆាំងការជួញដូរមនុស្ស

  -ចែកសៀវភៅសរសេរ ប៊ិក ខ្មៅដៃ និងក្រដាស

  -បញ្ចាំង Slide មេរៀន

  -ធ្វើតេស្តមុន និងក្រោយវគ្គ

  -សំណួរពិភាក្សា និងផ្លាស់ប្តូរយោបល់

  -ការអនុវត្តតួនាទីជាអ្នកសម្ភាសន៍ប្រើប្រាស់ទម្រង់វែង និងទម្រង់ខ្លី

  -លេងល្បែងថាមពល

  -ការប្រកួតឆ្លើយសំណួររបស់សិក្ខាកាម ដោយបែងចែកជាក្រុម

  -បង្ហាញវីដេអូបទយកការណ៍អំពីការពពោះជំនួស និងភាគចិនពាក់ព័ន្ធនឹងកល់ល្បិច និងការអូសទាញជនរងគ្រោះ

  -ការវាយតម្លៃរបស់សិក្ខាកាមចំពោះគ្រូបង្គោល

  -ការឆ្លើយសំណួរដាក់ពិន្ទុបញ្ចប់វគ្គរបស់សិក្ខាកាម

-ប្រគល់លិខិតបញ្ជាក់ការសិក្សាដល់សិក្ខាកាម

៥.លទ្ធផលការវាយតម្លៃ នៃកាបណ្តុះបណ្តាល

- លទ្ធផលវាយតម្លៃមុនវគ្គ

មានការធ្វើតេស្តដល់សិក្ខាកាមមុនវគ្គបណ្តុះបណ្តាល សង្កេតឃើញថាលទ្ធផលធ្វើតេស្តមិនបានល្អទៅតាមការកំណត់ ពីព្រោះសិក្ខាកាមមិនទាន់យល់ និងមិនយល់ច្បាស់អំពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចកម្លាំងពលកម្មនៅឡើយ ។

-ពិន្ទុ ១០-១២ (ល្អ) មិនមាន = 0%

-ពិន្ទុ ៧-៩ (ល្អបង្គួរ) មានចំនួន ៩ នាក់ = ១២.៨៥%

-ពិន្ទុ ៥-៦ (មធ្យម) មានចំនួន ១៧ នាក់ = ២៤.២៨%

-ពិន្ទុ (ក្រោមមធ្យម) មានចំនួន ៤៤ នាក់ = ៦២.៨៧%

ក្រោយពីបានសិក្សាយ៉ាងយកចិត្តទុកដាក់ និងការបង្ហាត់បង្ហាញពន្យល់ពីគ្រូឧទ្ទេសយ៉ាងច្បាស់លាស់ តាមលំដាប់លំដោយ នៃមេរៀនដែលបានកំណត់រយៈពេល ០៣ថ្ងៃ រួចមក សិក្ខាកាមក៏បានធ្វើតេស្ត សង្កេតឃើញថាសិក្ខាកាមទទួលបានលទ្ធផលល្អប្រសើរ ។

-ពិន្ទុ ១០-១២ (ល្អ) មានចំនួន ២៣ នាក់ = ៣២.៨៦%

-ពិន្ទុ ៧-៩ (ល្អបង្គួរ) មានចំនួន ៣០ នាក់ = ៤២.៨៦%

-ពិន្ទុ ៥-៦ (មធ្យម) មានចំនួន ១០ នាក់ = ១៤.២៩%

-ពិន្ទុ (ក្រោមមធ្យម) មានចំនួន ៧ នាក់ = ១០%

**លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត** អគ្គលេខាធិការ គ.ជ.ប.ជ បានលើកឡើងពាក់ព័ន្ធនឹងការបណ្តុះបណ្តាលរយៈពេល៣ថ្ងៃនេះថា សិក្ខាកាមមានការយកចិត្តទុកដាក់ក្នុងការស្តាប់ការបកស្រាយ ពន្យល់របស់គ្រូឧទ្ទេស និងមានការគោរពសិទ្ធិ ឲ្យតម្លៃគ្នាទៅវិញទៅមកចូលរួមសហការ ចូលរួមចែករំលែកបទពិសោធន៍ជាក់ស្តែង បញ្ចេញមតិយោបល់ លើកជាសំណួរជាច្រើនដើម្បីបំពេញបន្ថែមដល់សមត្ថភាពការងាររបស់ពួកគាត់ ។ ចំពោះគ្រូឧទ្ទេស ក៏បានចែករំលែកបទពិសោធន៍ល្អៗ ពន្យល់បកស្រាយច្បាស់លាស់ទៅតាមមេរៀននីមួយៗរបស់ខ្លួន ។ **លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត** បានលើកឡើងបន្តថា ក្រោយពីបានឆ្លងកាត់វគ្គបណ្តុះបណ្តាល ៣ថ្ងៃនេះ សង្ឃឹមថាសិក្ខាកាមទាំងអស់នឹងយកចំណេះដឹង ជំនាញដែលទទួលបាននាពេលនេះទៅធ្វើការអនុវត្តបានល្អ និងចំគោលដៅ និងអាចចែករំលែកបទពិសោធន៍ ចំណេះដឹងទាំងនេះដល់មន្ត្រីមានសមត្ថកិច្ចតាមមូលដ្ឋានបន្តទៀត ។

**លោកស្រី គ្រីស្ទីន ផាក្ខ** ប្រធានបេសកកម្មអង្គការ IOM កម្ពុជា បានមានមតិក្នុងពិធីបិទវគ្គបណ្តុះបណ្តាលស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដោយ លោកស្រីបានបញ្ជាក់ថា បន្ទាប់ពីបានស្តាប់របាយការណ៍របស់ **លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត ប៊ុណ្ណ សំខាន់** អំពីលទ្ធផលវគ្គបណ្តុះបណ្តាលនេះ ដោយចំនួនជាង ៩០% ទទួលបានលទ្ធផលល្អ គឺសប្បាយរីករាយដែលសិក្ខាកាមមានការយល់ដឹងច្រើន ។ ជាចុងក្រោយ **លោកស្រី** បានលើកឡើងថា សូមកោតសរសើរ និងអរគុណចំពោះវីរៈភាពដឹកនាំដ៏ឈ្លាសវៃរបស់ **លោកជំទាវ ជូ ប៊ុនអេង** អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ អរគុណចំពោះក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អង្គការ IOM នៅតែបន្តចូលរួមសហការ គាំទ្រជាមួយរាជរដ្ឋាភិបាល និងគណៈកម្មាធិការជាតិ គ.ជ.ប.ជ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅកម្ពុជា ។

**លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានមានប្រសាសន៍នៅក្នុងពិធីបិទវគ្គបណ្តុះបណ្តាលនាថ្ងៃនេះថា ពិតជារីករាយចំពោះវត្តមានរបស់សិក្ខាកាមទាំងអស់ ដែលមានតួនាទីពាក់ព័ន្ធសំខាន់ ក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស មួយទៀតសង្កេត

ឃើញថា សិក្ខាកាមទាំងអស់មានការយកចិត្តទុកដាក់ ស្តាប់ តាមដាន វាយតម្លៃ ចូលរួមយ៉ាងផុលផុស ហើយអ្វីដែលពិសេស គឺមានការសួរដេញដោលដើម្បីឲ្យច្បាស់លាស់សម្រាប់យកទៅអនុវត្តជៀសវាងភាពស្រពេកស្រពិល នាំឲ្យមានការខុសឆ្គង ។ **លោកជំទាវ** បន្តថា សូមយកចំណេះដឹងថ្ងៃនេះទៅអនុវត្តឲ្យបានត្រឹមត្រូវ ហើយបើមានការខ្វះចន្លោះត្រង់ចំណុចណាខ្លះ សូមផ្តល់ព័ត៌មានមកយើងខ្ញុំ យើងនឹងរកដំណោះស្រាយដើម្បីកែតម្រូវ ជាងនេះទៅទៀត ក្នុងនាមយើងទាំងអស់គ្នាជាមន្ត្រីរាជរដ្ឋាភិបាល និងជាសាធារណៈ ដែលទទួលខុសត្រូវការងារក្នុងផ្នែកប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ត្រូវមានស្មារតីផ្តល់យុត្តិធម៌ តាមរយៈការកំណត់អត្តសញ្ញាណជនរងគ្រោះ ដើម្បីផ្តល់សេវាសមស្រប សូមកុំបំពានចម្លើយពួកគាត់ និងមិនត្រូវធ្វើការសន្និដ្ឋានដោយគ្រាន់តែមើលឃើញផ្ទាល់ភ្នែក ពីព្រោះរាជរដ្ឋាភិបាលនឹងផ្តល់ភាពយុត្តិធម៌ជូនជនរងគ្រោះ និងប្រជាពលរដ្ឋកម្ពុជា ។ អ្វីដែលរីករាយមួយទៀត គឺលទ្ធផលពេលបញ្ចប់វគ្គតាមរយៈការធ្វើតេស្ត និងវាយតម្លៃ ឃើញថាសិក្ខាកាមទាំងអស់មានការយល់ដឹងច្រើនអំពីមេរៀនដែលបានបង្ហាញដោយគ្រូឧទ្ទេស បើប្រៀបធៀបជាមួយការធ្វើតេស្តមុនវគ្គកាលពីថ្ងៃទី១ មានន័យថាសិក្ខាកាមយើងពិតជាបានខិតខំយកចិត្តទុកដាក់ផ្តោតលើមេរៀនប្រាកដមែន ។ **លោកជំទាវ** មានប្រសាសន៍បញ្ជាក់ជូនសិក្ខាកាមថា សូមធ្វើការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះ **សម្តេចក្រឡាហោម** ពីព្រោះលោក គឺជាអ្នកដឹកនាំសំខាន់ ក្នុងការដឹកនាំគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដ៏មានភាពឈ្លាសវៃ និងប៉ិនប្រសប់ ដែលពេលនេះ **សម្តេចក្រឡាហោម** បានផ្ទេរសិទ្ធិជូន **ឯកឧត្តមបណ្ឌិត ស សុខា** ដើម្បីបន្តដឹកនាំការងារនេះឲ្យមានប្រសិទ្ធភាព ។

ចុងបញ្ចប់ **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** គ.ជ.ប.ជ មានប្រសាសន៍ជូនពរ ឯកឧត្តម លោកជំទាវ ជាគណៈអធិបតី លោកស្រីប្រធាន អង្គការ IOM គ្រូឧទ្ទេស ក្រុមការងារបច្ចេកទេស ព្រមទាំងលោក លោកស្រី ដែលជាសិក្ខាកាមទាំងអស់ មានសុខ សុវត្ថិភាពក្នុងការធ្វើដំណើរ ទទួលជោគជ័យគ្រប់ភារកិច្ច និងសូមជួបនូវពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

បន្ទាប់ **លោកជំទាវ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានផ្តល់កិត្តិយសចែកលិខិតបញ្ជាក់ការសិក្សាជូនសិក្ខាកាមទាំង ០២ ខេត្ត ដែលមានចំនួន ៧០ រូប ។ វគ្គបណ្តុះបណ្តាលរយៈពេល ០៣ថ្ងៃ បានបញ្ចប់ដោយជោគជ័យ ក្រោមបរិយាកាសសប្បាយរីករាយ ។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើសូម **លោកជំទាវ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ ។

ថ្ងៃចន្ទ ១២កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៣

**អ្នកធ្វើរបាយការណ៍**

វរសេនីយ៍ឯក សៅ ស៊ីនួន

**គោរពជូន**

**លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ**

**និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ ។

ថ្ងៃចន្ទ ១២កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៣

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯក វេជ្ជ.ប៊ុណ្ណ សំខាន់

បានឃើញ 28/08/23

ជួ_ប៊ុនអេង